# *Times-Picayune:* ការទាមទារសំណង ដែលលោក Kenneth Feinberg និយាយថាល្បឿននៃការទូរទាត់សងមានសន្ទុះឡើង

បោះពុម្ពផ្សាយ៖ ថ្ងៃច័ន្ទ ទី២០ ខែមិថុនា ឆ្នាំ២០១១ ម៉ោង ១១យប់

ដោយ **David Hammer,** ***Times-Picayune***

ការសាកសួរតាមនីតិក្រម និងភាពមិនទុកចិត្តនៅកើតមាន ក៏ប៉ុន្តែដើម្បីចង់ស្តាប់ការទាមទារសំណង ពីការហៀប្រេង លោក **Kenneth Feinberg**បាននិយាយឡើង-- និងដើម្បីពិនិត្យមើលស្ថិតិមកពីស្ថាប័នសម្របសម្រួលពាក្យបណ្តឹងទាមទារសំណងសម្រាប់តំបន់ឆ្នេរ ជាប់ឈូងសមុទ្រ (GCCF)របស់គាត់ --**ដំណើរការទាមទារការទូរទាត់សំណង** ដែលគាត់កាន់កាប់ នៅចុងបញ្ចប់ក៏សំរេចបាននូវ ជំហ៊ានដ៏វែងរបស់គាត់។

Feinberg, ដែលទទួលរងខូច ខាតកាលពីឆ្នាំទៅមិញដោយ BP និងសេត្តវិមាន ដើម្បីចាត់ការ ការទូរទាត់ការខូចខាតសេដ្ឋកិច្ច បានដោះ ស្រាយសំណងជិត ១៥០ ០០០ ករណី ហើយបានចំណាយប្រាក់អស់ជិត ៤.៥ពាន់លានដុល្លារ។

ទឹកប្រាក់ស្ទើរតែ ទាំងអស់នោះ គឺ ២.៦ពាន់ លានដុល្លារ បានចំណាយនៅក្នុងឆ្នាំ ២០១០ ជាផ្នែកនៃដំណាក់កាលការទូរទាត់សម្រាប់សង្រោះបន្ទាន់។ វាប្រើពេលវេលាដល់ទៅបួនខែដើម្បីទូរទាត់ប្រាក់មួយពាន់លានដុល្លារដំបូងក្នុង "ដំណោះស្រាយចុងក្រោយ" នៅឆ្នាំនេះ ការទូរទាត់ស្ទើរតែទាំងអស់បានប្រើប្រាស់ដំណើរការទូរទាត់រហ័សដែលរៀបចំឡើងដើម្បីអោយ មានភាពងាយស្រួលបំផុត មិនមានការបង់ថែមបន្តទៀត។

ក៏ប៉ុន្តែក្នុងរយៈពេលពីរខែចាប់ពីថ្ងៃទី ២០ ខែមេសា ដែលកំណត់ថាជាខួបលើកដំបូងនៃការហៀរបំផ្លាញរបស់ BP ប្រតិបត្តិការរបស់ Feinberg បានបង់ប្រាក់ អស់ប្រហែលជា ៧០០លានដុល្លារ សំរាប់សំណងណាដែលស្មុគស្មាញ --

សំណាងណាដែល ទាមទារការពិនិត្យពិច័យពេញលេញ និងមានឯកសារគ្រប់គ្រាន់ -- ហើយការចំណាយជាមធ្យមមានការកើន ឡើងថេរ។

នៅថ្ងៃគំរប់ខួប សំណាងចុងក្រោយមធ្យមគឺ ១៦ ០០០ដុល្លារ។ ឥឡូវនេះកើនឡើងជិតដល់ ២០ ០០០ដុល្លារហើយ។

នៅថ្ងៃគំរប់ខួប Feinberg ទើបតែបង់បាន ១១% នៃសំណើរទូរទាត់ចុងក្រោយនោះទេ។ ចំនួននោះបានកើនដល់ ២៦%នាពេលបច្ចុប្បន្ន ហើយ GCCF បានផ្តល់អោយរហូតដល់ជិតពាក់កណ្តាលនៃ អ្នកស្វែងរកការទូរទាត់សំណាងចំនួន ១១៥ ០០០នាក់ ដែលពួកគាត់មានពេល៩០ថ្ងៃដើម្បីទទួលយកអ្វីដែលលោក Feinberg ផ្តល់អោយ។

នៅថ្ងៃគំរប់ខួប សំណួរលើដំណើរការនោះគឺ: តើមានអ្នកប្តឹងតវ៉ាចំនួនប៉ុន្មាននាក់នឹងទទួលយកសំណើរចុងក្រោយពីលោក Feinberg ជាជាងរងចាំទទួល យកអ្វីលើសពីនោះទៅទៀតតាមរយៈតុលាការ?

ដោយមានទេសចរតាមឆ្នេរមានដំណើរការឡើងវិញ ឥឡូវនេះក្នុងមួយថ្ងៃៗកន្លងផុតទៅ ទំនងជាធ្វើអោយលោក ឈានទៅរកគោលដៅរបស់ខ្លួនដែល បានថែង អំពីការផ្តល់សេវាអោយបាន ៩០%នៃអ្នកប្តឹងតវ៉ាស្របច្បាប់ទាំងនោះ។ ហើយមានការចោទសួរដល់ BP នៅចំពោះមុខតុលាការរបស់ដើមបណ្តឹងរាប់ម៉ឺននាក់ដែលពុំទាន់បាន ដាក់ពាក្យ បណ្តឹងបានត្រឹមត្រូវចំពោះលោក Feinberg បណ្តឹងឧទ្ធរណ៍របស់ GCCF កាន់តែមានភាពរឹងមាំ ជាងមុន។

ការប្តឹងទាមទារបានប្រព្រឹត្តទៅជាង៩៥%នៃបណ្តឹងចំនួន៣០០ ០០០ដែល បានប្តឹងតវ៉ាមុនដំនាច់ខែ ឧសភា។ ក្រុមរបស់ Feinberg ចាត់ទុកថាប្រហែលជា ៤០%នៃបណ្តឹង ទាំងនោះមិនពេញលេញ រឺ មិនគ្រប់លក្ខណៈអាចប្តឹងបាន។ ប៉ុន្តែលោក Feinberg មានប្រសាសន៍ថា បណ្តឹងតវ៉ាផ្សេងទៀតដែល GCCF នៅកំពុងដោះស្រាយជាមួយ នោះ បានដាក់ពាក្យតាំងពីមុនខែនេះទៅទៀត ហើយជាពាក្យបណ្តឹងដែលមាន ភាពស្មុគស្មាញខ្លាំងណាស់។

ចំនួនពាក្យបណ្ដឹងថ្មីៗដែលបានដាក់ប្ដឹងបានបង្អង់ល្បឿនទៅរកភាពរាំងស្ទះ។

មានអ្នកប្ដឹងតវ៉ាតែចំនួន៥៤ ០០០នាក់ប៉ុណ្ណោះដែលស្វែងរកសំណងចុងក្រោយដែលលោក Feinberg ចាត់ទុកថាយកជាការបាន។ ប្រសិនបើការប្ដឹងទាមទារថ្មីមានភាពហ្នឹងហ្នរហើយនោះ ហើយលោក Feinberg បន្តបង់ការតវ៉ានៅក្នុងអត្រា មួយដែលគាត់បានអនុវត្តក្នុងចន្លោះពីរខែចុងក្រោយនេះ នោះគាត់នឹងអាចទូទាត់រាល់ការតវ៉ា ទាំងអស់ ដែលគាត់គិតថា ត្រឹមត្រូវនោះចប់នៅក្នុងរយៈពេលបួនខែទៀតជាមិនខាន។ ហើយបើទោះជាការកើនឡើងនៃអត្រាបង់នៅថេរពីពេលនេះទៅ នោះក៏មានន័យថាចំនួនទឹកប្រាក់មានរហូត ដល់១.១ពាន់លានដុល្លារទៀតរហូតដល់ថ្ងៃបុណ្យហាឡូវីន។

សំណួរយឺតយ៉ាវធំបំផុតមួយនោះគឺ: តើមានការទាមទារអ្វីបន្ថែមទៀតនៅទីនោះ? អ្វីដែលនៅសល់មិនច្បាស់លាស់ភាគច្រើនក្នុងឧស្សាហកម្មនេសាទ ជាកន្លែងដែលមានការវាស់វែងពិត ប្រាកដរបស់ការខូចខាតសេដ្ឋកិច្ចនៃការហៀរបំផ្លាញនោះកំពុងមានការលាតត្រដាងឡើង។ ត្រឹមតែ២៤ ០០០ អ្នកនេសាទត្រី ក្ដាម បង្គារ ម៉ឹក និងអ្នកផលិតអាហារសមុទ្រទេដែលបានជួបប្រទះកន្លងមក និងពាក់កណ្ដាលបានដោះស្រាយរួចរាល់ហើយ។ ចំនួនដ៏ច្រើនរបស់ពួកគេ -- ប្រហែល ១១ ០០០ករណី -- បានទទួលជំរើសទូទាត់រហ័សគឺ ៥ ០០០ដុល្លារ សំរាប់ បុគ្គល និង ២៥ ០០០ដុល្លារសំរាប់ក្រុមហ៊ុន។

ទោះជាយ៉ាងណាក៏ដោយតួលេខសំណង ការនេសាទ អាចមានការកើនឡើងខ្លាំង ប្រសិនបើលោក Feinberg និងអ្នកតំណាងឧស្សាហកម្មអាច មានការព្រមព្រៀង គ្នាលើការប្រែប្រួលចំពោះការគណនាការទូទាត់សងរបស់ GCCF។ ឧទាហរណ៍: លោក Feinberg មានប្រសាសន៍ថា គាត់និងបុគ្គលិករបស់គាត់កំពុងតែដោះស្រាយតាម "វិធីសាស្ត្រអធ្យាស្រ័យខ្ពស់" សំរាប់អ្នកនេសាទម៉ឹក ដែលនោះអាចនឹង "ឆ្លុះបញ្ចាំងថាអនាគតសត្វម៉ឹកនៅ

តាមឈូងសមុទ្រដូចដែលយើងនិយាយនៅតែមិនប្រាកដនៅរយៈពេលមួយឆ្នាំក្រោយមក”។

ប្រសិន បើវិធី គណនាមានការប្រែប្រួល លោក Feinberg សន្យាថាអ្នកនេសាទម៉ឹកដែលទទួលយកការទូរទាត់របស់ តាមប្រព័ន្ធចាស់នឹងទទួលបានសំណងផ្សេងទៀត។

វិធីសាស្ត្ររបស់លោក Feinberg ក្នុងខែកុម្ភៈមានការយោគយល់ច្រើនចំពោះអ្នកនេសាទម៉ឹកជាងអ្នកដ៏ទៃទៀត ដែលបានផ្តល់អោយពួកគាត់ ចំនួនបួនដងនៃការខាតបង់កាលពីឆ្នាំ២០១០ មិនត្រឹមតែពីរដងនៃការខូចខាតទាំងអស់ នោះទេ។ Mike Voisin ជាម្ចាស់ហាងអាហារសមុទ្រឈ្មោះ Motivatit Seafood និងជាអ្នកចរចារសំខាន់ម្នាក់ជាមួយ នឹង ក្រុមប្រឹក្សាឧស្សាហកម្មម៉ឹកឈូងសមុទ្រ និងអ្នកបោះដុំម៉ឹកនៅរដ្ឋ Louisiana និងសមាគមន៍ Growers បានមានប្រសាសន៍ថាការគណនាតាមរូបមន្ត គុណនឹងបួនដងនោះមិនមែនជាបញ្ហានោះទេ។ ការប្រើប្រាស់ប្រតិទិនឆ្នាំ២០១០គឺ។

ពីព្រោះថារដូវម៉ឹកចាប់ផ្តើមនៅខែកញ្ញា និងប្រព្រឹត្តទៅរហូតដល់ និទាឃៈរដូវបន្ទាប់ ពាក់កណ្តាលនៃរដូវម៉ឹក ២០១០-២០១១ ស្ថិតនៅក្រៅការគណនា ពីព្រោះវាតាមពិត ទៅគឺមិនដូចការពិតនោះទេ។ ឥឡូវនេះពេញមួយឆ្នាំបានកន្លងផុតទៅហើយ ក្រុមរកម៉ឹកចង់ប្រៀបធៀបប្រាក់ចំណូលពីខែមេសាដល់មេសា របស់ពួកគេទៅនឹងឆ្នាំមុនៗដើម្បីគណនាការខាតបង់ពិតប្រាកដដោយសារការហៀរប្រេងនោះ បន្ទាប់មក យកចំនួននោះទៅគុណនឹងបួនដង។ Voisin មានជំនឿថាលោក Feinberg នឹងយល់ព្រមតាមសំណើរនោះ ហើយនៅពេលដែលគាត់ធ្វើ ហើយអ្នកនេសាទម៉ឹកនោះ នឹមានបំណងបញ្ចប់ការទាមទាររបស់ពួកគេ។

Voisin និយាយថា “ខ្ញុំគិតថា នឹងធ្វើអោយត្រឹមត្រូវនិងច្បាស់លាស់ជាទីបំផុត”។ “យើងមានភាគីទទួលខុសត្រូវមួយដែលខ្ញុំជឿថានឹងដើរតួទទួលខុសត្រូវក្នុងករណីនេះ។ តើប្រជាជននឹងមានការខកចិត្តចំពោះបញ្ហានេះដែរឬទេ? ប្រាកដជាដូច្នោះហើយ។

អ្នកមានការតវ៉ាជាច្រើន វានឹងមានការរន្ធត់ខ្លាំង បើទោះជាលោក Ken Feinberg ក៏ដោយ។ ក៏ប៉ុន្តែជាលក្ខណៈរួម ខ្ញុំគិតថាប្រជាជននឹងក្លាយជាអ្នកនាំអោយគាត់សប្បាយរីករាយនៅទីបញ្ចប់។

អ្នកដ៏ទៃ មិនចែករំលែកសុទិដ្ឋិនិយមរបស់ Voisin នោះទេ។ បណ្តារអ្នកគ្រប់គ្រងករណីសប្បុរសធម៌កាតូលិក និយាយថាពួកគេមិនឃើញថាអ្នកនេសាទ ១៣០០នាក់ ដែលបានរាយការណ៍ថាទទួលការពិនិត្យពិច័យពេញលេញសំរាប់សំណងចុងក្រោយពីលោក Feinberg នេះ ច្រើនពេកនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានឃើញអ្នកនេសាទរាប់សិបពាន់នាក់ដែលត្រូវបានគេបដិសេធន៍ មិនព្រមទូរទាត់អោយជាបណ្តោះអាសន្នតាមត្រីមាស។

តាមច្បាប់សហព័ន្ធតម្រូវអោយលោក Feinberg បង់រាល់ការខាតបង់ជាបន្តបន្ទាប់ដោយពុំបង្ខំអោយអ្នកតវ៉ាចុះហត្ថលេខាលើប្តឹងអ្វីនោះឡើយ។ ប៉ុន្តែ គាត់បានធ្វើការទូរទាត់ត្រឹមតែចំនួន ១៦០០០ករណីប៉ុណ្ណោះ។

Tom Costanza នៃសប្បុរសធម៌ កាតូលិកបាននិយាយថា ភាគច្រើននៃសំណងចំពោះមុខមានចំនួនតិចតួចណាស់ ហើយត្រូវភ្ជាប់វា សម្រាប់ការទូរទាត់ចុងក្រោយ។ បើទោះជាការផ្តល់អោយចុងក្រោយទាំងនោះមិនសូវស៊ីគ្នាទៅនឹងអ្វីដែលអ្នកតវ៉ាស្នើរសុំនោះក៏ដោយ លទ្ធភាពនៃត្រីមាសមួយទៀតដោយគ្មានជំនួយគឺពិតជាពិបាកធានាបានណាស់។

គាត់មានប្រសាសន៍ ថា ៧០% នៃអ្នកតវ៉ាបានត្រឡប់ទៅរកទីប្រឹក្សាជំនួយបច្ចេកទេសហិរញ្ញវត្ថុរដ្ឋដើម្បីជួយ គឺនៅកំពុងរងចាំការដោះស្រាយ។

Costanza មានប្រសាសន៍ថា “ខ្ញុំគ្រាន់តែមិនអាចឃើញវិធីដែលបញ្ហានេះដើរចូលតាមគន្លងត្រឹមត្រូវនោះទេ”។

ភាពតានតឹងត្រូវបានគេប្រកាសនូវការទាមទារគ្រប់គ្រាន់ បញ្ហាចំបងមួយនៅ

ចំកណ្តាលសហគមន៍អ្នកនេសាទនានា របស់ជនជាតិវៀតណាមនៅតាមឆ្នេរជាប់ឈូងសមុទ្រ។